សេចក្តីណែនាំបង្ហាញ និង ទោសបញ្ញត្តិនៃរបាយ ការណ៍លក្ខណសម្បត្តិ/ស្ថានភាពទទួលជំនួយ

សំរាប់ជំនួយ CalWORKs និង ជំនួយ CalFresh

ត្រូវការជំនួយ? សូមទូរស័ព្ទទៅអ្នកកាន់សំណុំរឿងរបស់អ្នក

- បើអ្នកមិនផ្ញើមកនូវរបាយការណ៍ដែលបំពេញសព្វគ្រប់ រួមទាំង ប៉ុន្តែមិនកំរិតត្រឹមតែ ឆ្លើយនូវសំណួរទាំងអស់នៅក្នុងសំណៅ SAR 7 និង ភ្ជាប់នូវភស្តុតាងនៅពេលយើងសូររកឱ្យភ្ជាប់នូវភស្តុតាងទេនោះ ជំនួយរបស់អ្នកប្រហែលជាអាចពន្យារ ផ្លាស់ប្តូរ ឬបញ្ឈប់បាន ។ **សូមភ្ជាប់នូវទំព័របន្ថែម បើសិនជាត្រូវការ ។**
- ព័ត៌មានដែលអ្នករាយការណ៍ ប្រហែលជាអាចបណ្តាលឱ្យជំនួយរបស់អ្នក កើនឡើង ថយចុះ ឬ ត្រូវបញ្ឈប់បាន ។
- សូមផ្ញើនូវរបាយការណ៍ដែលបំពេញសព្វគ្រប់របស់អ្នក នៅថ្ងៃទី 5th នៃខែ បន្ទាប់ពី ខែដែលបានរាយការណ៍ ។ វានឹងត្រូវចាត់ទុកជាយឺតយ៉ាវ ក្រោយថ្ងៃទី 11th ។

ឧទាហរណ៍

ប្រាក់ចំណូល

- ប្រាក់ខែ
- ប្រាក់សំរាប់ពេលវិស្សមកាល
- ប្រាក់ពីសេវាការមើលថែទាំក្នុងផ្ទះ (IHSS)
- ប្រាក់ជួយឧបត្ថម្ភកូន/ប្តីប្រពន្ធ
- ប្រាក់ពីក្រុមហ៊ុនធានារ៉ាប់រង ឬ ប្រាក់ទទួលបានក្រោយការសម្រះសម្រួលតាមផ្លូវច្បាប់
- ប្រាក់ចំណូលនៃការជួលផ្ទះ និង ជំនួយខាងទីលំនៅ
- ជំនួយនានាពីរដ្ឋ
- ការធានារ៉ាប់រងពិការភាពរដ្ឋ
- ការធ្វើជំនួញដោយខ្លួនឯង
- ប្រាក់ទឹកតែ
- ការប្រាក់ ឬប្រាក់ចំណែកភាគហ៊ុន
- ផលប្រយោជន៍ពេលធ្វើកូដកម្ម
- ប្រាក់ពន្ធផ្តល់ឱ្យវិញ
- ប្រាក់ជំនួយពេលគ្មានការងារធ្វើ
- ប្រាក់សូស្យាល់សឺគូរីទី
- ប្រាក់ជំនួយបន្ថែមសូស្យាល់សឺគូរីទី/ប្រាក់ជំនួយបន្ថែមពីរដ្ឋ (SSI/SSP)
- ប្រាក់បៀវត្សរ៍
- ប្រាក់សប្បរស ដូចជា ប្រាក់ចំណូលដោយផ្នូរលើកិច្ចការងារសំរាប់ថ្លៃផ្ទះ, ថ្លៃផ្ទះ/ទឹក ភ្លើង ហ្គាស/សំលៀកបំពាក់/ម្ហូបអាហារ ដែលគេចេញឱ្យ
- ប្រាក់ឈ្នះល្បែង/ឈ្នះឆ្នោត
- លុយសុទ្ធ អំណោយ លុយកម្ចី អាហារូបករណ៍
- ប្រាក់ជំនួយដទៃទៀតសំរាប់អ្នកពិការ ឬអ្នករឺត្រែតបានមកពីអង្គការឯកជន ឬរដ្ឋ
- ប្រាក់ធានាសំរាប់ពេលមានគ្រោះថ្នាក់នៅកន្លែងធ្វើការ
- ប្រាក់រឺត្រែតសំរាប់អតីតយុទ្ធជន ឬ អតីតអ្នកធ្វើការរថភ្លើង

ទ្រព្យសម្បត្តិ

- យានយន្ត
- ប្រាក់សល់ក្នុងគណនី EBT
- ផ្ទះ
- គណនីសែក
- ប្រាក់សន្សំភាគហ៊ុន
- ដីធ្លី
- គណនីសន្សំ
- កិច្ចសន្យាធានារ៉ាប់រងជីវិត
- ប្រាក់ធានាសន្សំទុក

ប្រាក់ចំណាយលើទីលំនៅ

- ថ្លៃជួលផ្ទះ
- ថ្លៃ ទឹក ភ្លើង ហ្គាស...
- ប្រាក់បង់ថ្លៃផ្ទះរ៉លោះ
- ប្រាក់បង់ការធានារ៉ាប់រងផ្ទះ
- ប្រាក់បង់ថ្លៃពន្ធដារផ្ទះ
- ប្រាក់បង់ថ្លៃចាក់សំរាម/ប្រមូលសំរាម

ប្រាក់ចំណាយផ្សេងៗ

- ថ្លៃថែទាំសុខភាព
- ថ្លៃការធានារ៉ាប់រងសុខភាព
- ថ្លៃមើលថែទាំកូន/អ្នកនៅក្នុងបន្ទុក
- ថ្លៃបង់មហាវិទ្យល័យ និងសម្ភារៈសិក្សា
- ថ្លៃសម្ភារៈសំរាប់សាលា
- ប្រាក់បង់ជួយឧបត្ថម្ភកូន/ប្តីប្រពន្ធ
- ថ្លៃយានជំនិះ
- ថ្លៃបន្ទប់ និងអាហារ
- ថ្លៃទីលំនៅ

ប្រាក់ចំណូលសរុបមានន័យថា ចំនួនសរុបដែលអ្នកទទួល នៅមុនពេលការដកហូតផ្សេងៗត្រូវបានដកចេញ (ឧទាហរណ៍នៃការដកហូតទាំងនោះគឺ: ពន្ធដារ សូស្យាល់សឺគូរីទី ឬ ប្រាក់រឺត្រែតដទៃៗទៀត ថ្លៃបង់ការធានារ៉ាប់រងសុខភាព បណ្តឹងរឹបទ្រព្យពីតតីយជននានា ។ល។) ។

ទោសបញ្ញត្តិ:

ទោសបញ្ញត្តិសំរាប់ការបន្លំលើជំនួយ CalWORKs: បើ ដោយចេតនា អ្នកមិនធ្វើតាមបញ្ញត្តិជំនួយ CalWORKs ជំនួយ CalWORKs របស់អ្នកអាចត្រូវគេកាត់បន្ថយសំរាប់ពេលមួយរយៈ ហើយ អ្នកប្រហែលជាត្រូវគេពិន័យជាទឹកប្រាក់រហូតទៅដល់ $10,000 និង/ឬ បញ្ជូនទៅមន្ទីរឃុំឃាំង ឬ ពន្ធនាគារ៉ រហូតដល់ទៅ 3 ឆ្នាំ ។

ជំនួយ CalWORKs របស់អ្នកអាចត្រូវបញ្ឈប់:

- សំរាប់ការមិនរាយការណ៍ព័ត៌មានពិតទាំងអស់ ឬផ្តល់ព័ត៌មានមិនពិត: 6 ខែ សំរាប់ការរំលោភលើកទីមួយ 12 ខែ សំរាប់ការរំលោភលើកទីពិរ ឬ មិនបានទទួលជំនួយ ជារៀងរហូតតទៅ សំរាប់ការរំលោភលើកទីបី ។
- សំរាប់ការដាក់ពាក្យសុំម្តង ឬច្រើនជាងហ្នឹង ដើម្បីទទួលជំនួយពីសំណុំរឿងច្រើនជាងមួយ ក្នុងរយៈពេលតែមួយ: 2 ឆ្នាំ សំរាប់ការជាប់ទោសលើកទីមួយ 4 ឆ្នាំ សំរាប់ការជាប់ទោសលើកទីពិរ និង ជារៀងរហូតតទៅ សំរាប់ការជាប់ទោសលើកទីបី ។
- សំរាប់ការជាប់ទោសបទឧក្រិដ្ឋដោយការបន្លំ ដើម្បីទទួលជំនួយ: 2 ឆ្នាំ សំរាប់បទលួចប្រាក់ចំនួនក្រោម $2,000; 5 ឆ្នាំ សំរាប់បទលួចប្រាក់ចំនួន $2,000 ដល់ $4,999.99; និង ជារៀងរហូតតទៅ សំរាប់ និងជារៀងរហូតតទៅ សំរាប់បទលួចប្រាក់ចំនួន $5,000 ឬច្រើនជាងហ្នឹង ។
- ជារៀងរហូតតទៅ: សំរាប់ការផ្តល់ជូនខោនធីនូវព័ត៌មានមិនពិតអំពីទីលំនៅ ដើម្បីទទួលជំនួយក្នុងខោនធី ឬរដ្ឋចំនួនពីរ ឬច្រើនជាងហ្នឹង ក្នុងរយៈពេលតែមួយ; ការផ្តល់ជូនខោនធីនូវព័ត៌មានមិនពិតអំពីកូនដែលគ្មានលក្ខណសម្បត្តិទទួលជំនួយ ឬកូនដែលមិនមាននៅក្នុងគ្រសារ; ទទួលប្រាក់ជំនួយច្រើនជាង $10,000 ដោយការបន្លំ; ទទួលការជាប់ទោសលើកទីបី ដោយការបន្លំដែលបានសម្រេចដោយសាលាក្តី ឬដោយសវនាការបំភ្លឺរដ្ឋបាលមួយ ។

ទោសបញ្ញត្តិសំរាប់ការបន្លំលើជំនួយ CALFRESH: បើ ដោយចេតនា អ្នកមិនធ្វើតាមបញ្ញត្តិជំនួយ CalFresh ជំនួយ CalFresh របស់អ្នកអាចត្រូវគេ កាត់ផ្តាច់ចំនួន 12 ខែ សំរាប់ការរំលោភច្បាប់លើកទីមួយ 24 ខែ សំរាប់ការរំលោភច្បាប់លើកទីពីរ និង មិនបានទទួលជំនួយជារៀងរហូតតទៅ សំរាប់ការរំលោភច្បាប់លើកទីបី ។ អ្នកប្រហែលជាត្រូវគេពិន័យជាទឹកប្រាក់រហូតទៅដល់ $250,000 និង/ឬ បញ្ជូនទៅមន្ទីរឃុំឃាំង/ពន្ធនាគារ៉ រហូតដល់ទៅ 20 ឆ្នាំ ។ បើ អ្នកត្រូវគេរកឃើញថាមានទោសដោយសាលាក្តី ឬដោយសវនាការបំភ្លឺរដ្ឋបាលណាមួយ ព្រោះតែ:

- អ្នកដូរ ឬលក់ជំនួយ CalFresh សំរាប់ទិញកាំភ្លើងដៃ គ្រាប់រំសេវ ឬគ្រឿងផ្ទះ ជំនួយ CalFresh របស់អ្នកអាចត្រូវគេកាត់ផ្តាច់ជារៀងរហូតតទៅ សំរាប់ការរំលោភច្បាប់លើកទីមួយ ។
- អ្នកដូរ ឬលក់ជំនួយ CalFresh សំរាប់គ្រឿងញៀន ជំនួយ CalFresh របស់អ្នកអាចត្រូវគេកាត់ផ្តាច់ចំនួន 24 ខែ សំរាប់ការរំលោភច្បាប់លើកទីមួយ និង ជារៀងរហូតតទៅ សំរាប់ការរំលោភច្បាប់លើកទីពីរ ។
- អ្នកដូរ ឬលក់ជំនួយ CalFresh ដែលមានតំលៃ $500 ឬច្រើនជាងហ្នឹង ជំនួយ CalFresh របស់អ្នកអាចត្រូវគេកាត់ផ្តាច់ជារៀងរហូតតទៅ ។
- អ្នកផ្តល់ជូនខោនធីនូវព័ត៌មានមិនពិតអំពីរូបអ្នក ឬទីលំនៅ ដូច្នេះ អ្នកអាចទទួលជំនួយ CalFresh ក្នុងសំណុំរឿងច្រើនជាងមួយ ក្នុងរយៈពេលតែមួយ ជំនួយ CalFresh របស់អ្នកអាចត្រូវគេកាត់ផ្តាច់ចំនួន 10 ឆ្នាំ ។